# ខ្លឹមសារសង្ខេប

សាលដីកាតុលាការកំពូលសហរដ្ឋអាមេរិក Lawrence v. Texas, 539 U.S. 558 (2003)

**ពាក្យគន្លឹះ៖** សិទ្ធិជីវិតឯកជន, គោលការណ៍មិនរើសអើង, យុត្តិសាស្ត្រ (precedent) និងការបដិសេធ, អំពីអនាចាររួមភេទជាមួយភេទដូចគ្នា (sodomy)

**សំណួរ៖** តើច្បាប់ដាក់ទោសទណ្ឌ ដល់បុរសរួមភេទនិងបុរស ដោយព្រមព្រៀង នៅក្នុងបន្ទប់ឯកជន ផ្ទុយនឹងធម្មនុញ្ញដែរឬទេ?

**១.** ប៉ូលីសចូលទៅទីតាំងដែលគេបានរាយការណ៍ ថាមានការប្រើប្រាស់កាំភ្លើង ហើយចៃដន្យបានប្រទះឃើញបុរសមួយគូកំពង់រួមភេទគ្នា ដោយព្រមព្រៀង នៅក្នុងបន្ទប់ឯកជន (កថាទី១)។ ប៉ូលីសបានធ្វើការចោទប្រកាន់ ហើយថៅក្រមបានសម្រេចដាក់ទោស តាមច្បាប់របស់រដ្ឋតិចសាស ដែលហាមឃាត់អំពើនេះ (កថាទី៥)។ សាលាឧទ្ធរណ៍នៃរដ្ឋតិចសាស បានតម្កល់សាលក្រមនេះ (កថាទី៦)។ ជនជាប់ចោទបានប្ដឹង ទៅតុលាការកំពូល ដោយអះអាងថា ច្បាប់ដាក់ទោសទណ្ឌដូចនេះ ផ្ទុយនឹងសិទ្ធិជីវិតឯកជន (right to privacy) និង គោលការណ៍មិនរើសអើង (equal protection of law) ដែលមានចែងក្នុងវិសោធនកម្មទី១៤ នៃច្បាប់ធម្មនុញ្ញរបស់សហរដ្ឋអាមេរិក។

**២.** រដ្ឋតិចសាស ដែលជាចុងចម្លើយបានចូលមកការពារច្បាប់របស់ខ្លួន ដោយស្នើសុំឲ្យតុលាការកំពូលសម្រេចសេចក្ដី ដោយយកតាមយុត្តិសាស្ត្រ Bowers v. Hardwick [(478 U.S. 186 (1986)]។ វាជាយុត្តិសាស្ត្ររបស់តុលាការកំពូលក្នុងរឿងស្រដៀងគ្នាប្ដឹងប្រឆាំងនឹងរដ្ឋ Georgia។

**៣.** តុលាការកំពូលត្រូវសម្រេចថា តើយុត្តិសាស្ត្រ នេះជាច្បាប់ដែលត្រូវយកមកអនុវត្ត ឬសំអាងក្នុងរឿងក្ដីនេះឬយ៉ាងណា (កថាទី៧)? តុលាការបានសម្រេចបដិសេធ ដោយផ្អែកលើមូលដ្ឋានជាច្រើន៖ **ក.** យុត្តិសាស្ត្រនេះ មានតាំងពី ១៧ ឆ្នាំមុន ពាក់ព័ន្ធនឹងការហាមឃាត់ដោយច្បាប់នូវអំពើអនាចាររួមភេទរវាងភេទដូចគ្នា។ ក្នុងន័យដើមច្បាប់នេះសំដៅបង្ការ ឬបង្ក្រាបអំពើអនាចារដោយមនុស្សពេញវ័យ ជាមួយកុមារ (មានលក្ខណៈបង្ខំ) និងផ្ទុយពីសីលធម៌ ដែលច្បាប់ត្រូវអន្តរាគមន៍តាមរយៈការដាក់ទោសទណ្ឌ (កថាទី២១)។ **ខ.** យុត្តិសាស្ត្រ Bowers v Hardwick ក៏ត្រូវបានថៅក្រមដែលសម្រេចមិនឯកភាពទាំងស្រុងទេ ហើយអ្នកសិក្សាជាច្រើនបានរិះគន់ (កថាទី៣៤ និង ៤០)។ យុត្តិសាស្ត្រនេះ មិនបានពិចារណាដល់សេចក្ដីសម្រេចរបស់ប្រទេសដទៃ ដូចជា អង់គ្លេស និងជាពិសេសសាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (Dudgeon v. United Kingdom, 45 Eur.Ct.H.R,1981) ក្នុងរឿងស្រដៀងគ្នានេះ បានសម្រេចថាច្បាប់របស់ អង់គ្លេស ផ្ទុយនឹងសិទ្ធិជីវិតឯជន (កថាទី ២៩ និង ៣០។ បន្ទាប់មកមានយុត្តិសាស្ត្រតុលាការកំពូលចំនួន២ របស់សហរដ្ឋអាមេរិកដែលសម្រេចក្រោយ Bowers បានបង្ហាញពីមន្ទិលខ្លាំងដល់ខ្លឹមសារសម្រេចរបស់ក្នុង Bowers (កថាទី ៣២)។ រដ្ឋចំនួន ២៥ ដែលបានហាមឃាត់អំពើអនាចាររួមភេទដូចគ្នា យោង

ក្នុងយុត្តិសាស្ត្រ *Bowers* បានថយមកដល់ ១៣ រដ្ឋ ហើយមានតែ ៤រដ្ឋតែប៉ុណ្ណោះ ដែលអនុវត្តច្បាប់ជាក់ស្តែង (កថាទី ៣១) ។ ជាពិសេសទៅយុត្តិសាស្ត្រ Bowers មិនមានអង្គហេតុដូចគ្នាទាំងស្រុងនឹងរឿងនេះទេ ដោយសារក្នុងរឿងនោះ ច្បាប់រដ្ឋ Georgia ហាមឃាត់អំពើអនាចារទាំងពីរភេទ ដែលខុសពីរឿងនេះ ចែងហាម និងដាក់ទោសអំពើអនាចាររវាងភេទដូចគ្នា ក្នុងច្បាប់រដ្ឋតិចសាស (កថាទី ១៥)។ នេះមានលក្ខណៈរើសអើង។ ជាចុងក្រោយ តុលាការកំពូលបានអះអាងថា ការជៀតជ្រែកលុះត្រាចាំបាច់៖ សិទ្ធិសេរីភាព ក្រោមបទប្បញ្ញត្តិវិធីត្រឹមត្រូវ (Due Process Clause) ផ្តល់ពួកគេ នូវការធានានូវនីតិវិធីច្បាប់ត្រឹមត្រូវ និង សិទ្ធិពេញលេញក្នុងការចូលរួមក្នុងទង្វើផ្ទាល់ខ្លួន ដោយគ្មានការអន្តរាគមពីអាជ្ញាធរ។ វាជាការសន្យាក្នុងរដ្ឋធម្មនុញ្ញថា៖ *មានវិស័យជីវិតឯកជន ដែលរដ្ឋាភិបាលអាចជ្រែកជ្រៀត។*[1] យុត្តិសាស្ត្រគ្រាន់តែជាគោលការណ៍នយោបាយ (principle of policy) ដែលអាចត្រូវបានបដិសេធ បើមានមូល ដ្ឋានរឹង មាំដូចខាងលើនេះ។[2]

៤. តុលាការបានសម្រេចថា៖ *សាលក្រមនៃសាលាឧទ្ធរណ៍ ..ត្រូវបដិសេធ ហើយសំណុំរឿងត្រូវបញ្ជូនត្រឡប់ទៅវិញ ដើម្បីបន្តនីតិវិធី ស្របតាមការសម្រេចនេះ។*[3]

**កំណត់សំគាល់៖ ក.** ក្នុងប្រព័ន្ធច្បាប់កំមុនឡ (common law) ទោះបីមិនមានច្បាប់ចែងជាបទល្មើស ក៏ចៅក្រមអាចសម្រេច ហើយបង្កើតជាយុត្តិសាស្ត្រ សម្រាប់ជានិយាមសម្រេច លើសំណុំរឿងមានអង្គហេតុស្រដៀងគ្នានាពេលក្រោយទៀត។ នេះខុសពីប្រព័ន្ធស៊ីវិលឡ (civil law) ដែលចៅក្រម ត្រូវសម្រេចដោយផ្អែកជាចម្បងទៅលើអត្ថិភាពនៃច្បាប់។ ទោះបីជាយ៉ាងនេះក្តី ដើម្បីធានានូវឯកភាពនៃការបកស្រាយច្បាប់ និងធានាសុវត្ថិភាពគត្តិយុត្ត ប្រទេសស៊ីវិលឡខ្លះ តុលាការកំពូល (ករណីវៀតណាម) ប្រទេសបារាំង បានសម្រេចជ្រើសរើសនូវសាលក្រមជាគំរូ សម្រាប់ចៅក្រមពិចារណា ក្នុងករណីមានអង្គហេតុនៃសំណុំរឿងដូចគ្នា។ នេះស្រដៀងនឹងយុត្តិសាស្ត្រ ក៏ប៉ុន្តែ គេប្រើពាក្យពេចន៍ខុសគ្នា ( Settled Jurisprudence)។ **ខ**. ដូចក្នុងរឿងនេះ តុលាការកំពូលបានបដិសេធ នូវយុត្តិសាស្ត្រចាស់ ដោយផ្អែកលើមូលដ្ឋានយ៉ាងរឹងមាំ។[4] **គ**. ក្នុងរឿងនេះ មានទំនាស់រវាងច្បាប់រដ្ឋ និងបទប្បញ្ញត្តិសិទ្ធិមនុស្ស (ជីវិតឯកជន) ដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ តុលាការ រកឃើញថា បទប្បញ្ញត្តិខុសពីរដ្ឋធម្មនុញ្ញ មិនមែនសន្និសញ្ញា

---

[1] *Their right to liberty under the Due Process Clause gives them the full right to engage in their conduct without intervention of the government. It is a promise of the Constitution that there is a realm of personal liberty which the government may not enter*, Casey, supra, at 847 (para.42).

[2] Bowers was not correct when it was decided, and it is not correct today. It ought not to remain binding precedent. Bowers v. Hardwick should be and now is overruled, para. 41.

[3] The judgement of the Court of Appeals for the Texas Fourteenth District is reversed, and the case is remanded for further proceedings not inconsistent with this opinion.

[4] This is the case notwithstanding the fact that the only direct appellate panel for the decisions of the DCIJ is the PTC and that in a civil law system such as that of Cambodia there is no doctrine of *stare decisis*. It would nonetheless be undesirable from the point of view of clarity and uniformity of the law in a legal environment as closed as that of the ECCC for judges lower in the court hierarchy to disregard the SCC case law unless there were exceptional reasons, ECCC, COIJ, Closing Order (reasons), Case 004/1, D308/3, 10 July 2017, para.10.

អន្តរជាតិទេ។ ប្រសិនបើក្នុងករណីច្បាប់ទំនាស់ជាមួយសន្ធិសញ្ញា សេចក្តីសម្រេចអាចមានខ្លឹមសារផ្សេងៗពីនេះ អាស្រ័យ ទៅតាមប្រព័ន្ធច្បាប់ក្នុងស្រុកនីមួយៗ ដែលអនុវត្តសន្ធិសញ្ញាអន្តរជាតិ។ **ឃ.** ក្នុងសំណុំរឿងនេះ ក៏មានបញ្ហាចោទពាក់ព័ន្ធនឹងច្បាប់មានចរិតរើសអើងផងដែរ។ សម្រាប់អត្ថន័យនៃពាក្យរើសអើង សូមមើល www.measboralaws.com ។